**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..៣៩..សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារដើម្បីទ្រទ្រង់ និងសំរបសំរួលដល់ការរៀបចំប្រគុំតន្ត្រីសប្បុរសធម៌ (Charity Concert) និងការរៀបចំទិវាបង្ហាញម៉ូដសំលៀកបំពាក់ (Fashion Show) នៅខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## <u>សំរេច</u>

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារដើម្បីទ្រទ្រង់ និងសំរបសំរួលដល់ការរៀបចំប្រគុំតន្ត្រីសប្បុរសធម៌ (Charity Concert) និងការរៀបចំទិវាបង្ហាញម៉ូតសំលៀកបំពាក់ (Fashion Show) នៅខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ថោង ខុន | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | ប្រធាន |
| ២-ឯកឧត្តម | ស៊ឹម សួង | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលការងារទេសចរណ៍ | អនុប្រធាន |
| ៣-ឯកឧត្តម | ឆែព ហែន | អគ្គនាយករងអាជ្ញាធរអប្សរា | អនុប្រធាន |

| | | | |
|---|---|---|---|
| ៤- លោក | ស៊ួស យ៉ារ៉ា | អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិកប្រចាំការ |
| ៥-ឯកឧត្តម | រស់ រ៉េន | អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៦-ឯកឧត្តម | ខា សុត្ថា | អនុរដ្ឋលេខាធិកា រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ៧-ឯកឧត្តម | ហាប់ សុត | អគ្គនាយក ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៨-ឯកឧត្តម ឧត្តមសេនីយ៍ឯក | គេខ សាទខ្ម | អគ្គនាយករងអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ | សមាជិក |
| ៩-ឯកឧត្តម | ខាំ សុខុម | អគ្គលេខាធិការរងគណៈកម្មាធិការអចិន្ត្រៃរៀបចំបុណ្យជាតិនិងអន្តរជាតិ | សមាជិក |
| ១០-លោក | ទាន់ សុផល | អភិបាលរងខេត្តសៀមរាប | សមាជិក |
| ១១-លោក | ឡាយ បូនី | នាយករងទីចាត់ការគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២-លោក | ឈឹម សុខុម | ប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ ក្រសួងទេសចរណ៍ | សមាជិក |
| ១៣-លោក | ឆាយ ថៃ | អនុប្រធាននាយកដ្ឋាន អាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិក |

**ប្រការ ២.-**

ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម:

- រៀបចំទីតាំងសម្តែងសិល្បៈ ទស្សនីយភាព
- រៀបចំទទួលភ្ញៀវជាតិ និងអន្តរជាតិ
- រៀបចំសន្តិសុខ និងសណ្តាប់ធ្នាប់
- សំរួលដល់ការហោះហើរ
- ការងារទាក់ទងទៅនឹងបែបបទចេញ-ចូល ផ្នែកទិដ្ឋាការ ផ្នែកគយ និងការងារផ្សេងៗទៀតទាក់ទងនឹងការធ្វើដំណើរ
- បូកសរុប រាយការណ៍ អំពីលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល

**ប្រការ ៣.-**

ការចំណាយក្នុងការរៀបចំទស្សនីយភាពសិល្បៈ ហូបចុក ដឹកជញ្ជូន ជាបន្ទុកទទួលខុសត្រូវរបស់ក្រុមហ៊ុន :

- Rafles Holding & Rafles International Limited
- Chosun ilbo times founder, Bang, eung-mo.Foundation association.

**ប្រការ ៤.-**

ក្រុមការងារមានសិទ្ធិបង្កើតអនុគណៈកម្មការតាមការចាំបាច់ ។

**ប្រការ ៥.-**

សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ ៦.-**

ក្រុមការងារនេះត្រូវចប់ភារៈកិច្ច និងត្រូវរំសាយជាស្វ័យប្រវត្តិនៅពេលចប់ទិវាទាំងពីរ ។

**ប្រការ ៧.-**

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ក្រុមការងារមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍។

**ប្រការ ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានអគ្គនាយកអាជ្ញាធរអប្សរា ប្រធានអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ សាលាខេត្តសៀមរាប ក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ព្រមទាំងឯកឧត្តមអស់លោក ដែលមានឈ្មោះក្នុងក្រុមការងារត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទការល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ